មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទជាស្ត្រី

www.cchrcambodia.org

លេខ១៥៖ ខែឧសភា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានធ្វើការសង្កេតការណ៍សវនាការចាប់តាំងពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌនៅតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌តាមបទដ្ឋានជាតិ និងអន្តរជាតិ។ ចាប់តាំងពីខែមីនា ឆ្នាំ២០១៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក បានសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ព្រឹត្តិបត្រព័ត៌មាននេះ គឺជាការចេញផ្សាយជាស៊េរីដែលវិភាគលើរបកគំហើញពីការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ ព្រឹត្តិបត្រព័ត៌មាននេះផ្តោតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទជាស្ត្រី រួមមានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ការឃុំខ្លួនបណ្តោះអាសន្ន សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី ព្រមទាំងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ព្រឹត្តិបត្រព័ត៌មាននេះរួមបញ្ចូលទាំងទិន្នន័យដែល ម.ស.ម.ក ប្រមូលបានតាមរយៈការសង្កេតការណ៍នៅឆ្នាំ២០២១ និងការប្រៀបធៀបជាមួយទិន្នន័យដែលប្រមូលកាលពីឆ្នាំមុនៗ។ ទិន្នន័យដែលប្រមូលបានទាំងអស់អាចស្វែងរកបានជាសាធារណៈនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់យើង។

### ភាពស្មើគ្នានៃបុរស និងស្ត្រីចំពោះមុខច្បាប់

ទាំងច្បាប់ជាតិ និងអន្តរជាតិធានាសមភាពរវាងបុរស និងស្ត្រីនៅចំពោះមុខច្បាប់។ ហេតុដូច្នេះ ច្បាប់ទាំងនេះផ្តល់ការការពារដោយស្មើភាពចំពោះជនជាប់ចោទទាំងអស់ ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ រួមទាំងជនជាប់ចោទជាស្ត្រីផងដែរ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មិនកំណត់អំពីយេនឌ័រ រីឯមាត្រា ៤៥ ចែងអំពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងចែងថា បុរសនិងស្ត្រីមានសិទ្ធិ"ស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់"។ សមភាពរវាងបុរស និងស្ត្រីនៅចំពោះមុខច្បាប់ក៏ត្រូវបានធានានៅមាត្រា ១៥(១) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង

> *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
> *មាត្រា ៣១*
>
> "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"

ប្រឆាំងនឹងស្ត្រីភេទ ("ស៊ី-ដ") ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ មាត្រា ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលប្រទេសកម្ពុជាជាភាគី ក៏ធានាសមភាពនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់បុរស និងស្ត្រីផងដែរ។

បន្ថែមលើនេះ យោងតាមមាត្រា ២ នៃ ក.អ.ស.ព.ន កម្ពុជាត្រូវតែគោរព និងធានាការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅមាត្រា ១៤ និងចាត់វិធានការចាំបាច់ដើម្បីអនុម័តច្បាប់ ឬចំណាត់ការចាំបាច់ផ្សេងទៀតដើម្បីធ្វើឱ្យមានប្រសិទ្ធភាពចំពោះសិទ្ធិទាំងនោះ។

ខណៈដែលបុរស និងស្ត្រីប្រឈមនឹងបញ្ហាដូចគ្នានៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា តែផលប៉ះពាល់បានជះឥទ្ធិពលយ៉ាងខ្លាំងលើស្ត្រី ហេតុដូចនោះ ចាត់ទុកថាជាការរើសអើងយ៉ាងជាក់ច្បាស់។ ស្ត្រីនៅតែបន្តជួបការប្រឈមនឹងការទទួលបានយុត្តិធម៌ ហើយជនជាប់ចោទជាស្ត្រីទទួលបានការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេនៅមានកម្រិតនៅឡើយ។ បន្ថែមលើនេះ ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ដែលក្នុងនោះស្ត្រីនៅមានចំនួនតិចខ្លាំង ខ្វះការគិតគូរយកចិត្តទុកដាក់លើយេនឌ័រ រារាំងទាំងជនរងគ្រោះ និងជនជាប់ចោទជាស្ត្រីពីការទទួលបានយុត្តិធម៌ពេញលេញ។

### ការឃុំខ្លួនជនជាប់ចោទជាស្ត្រីបណ្តោះអាសន្ន

លក្ខណៈពិសេសនៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ត្រូវបានការពារដោយមាត្រា ២០៣ និងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែជាការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ន គឺត្រូវធ្វើស្ទើរតែទាំងអស់លើស្ត្រីដែលជាម្តាយមានកូនតូច ឬមានផ្ទៃពោះ។ ស្ត្រីជាម្តាយ អាចងាយរងគ្រោះដែលបណ្តាលមកពីការរំលោភបំពានសិទ្ធិរបស់ពួកគេ និងការជាប់ពន្ធនាគារដែលម្តាយត្រូវបានបំបែកចេញពីកូនរបស់ខ្លួន ឬដែលកូនរបស់ពួកគេនៅក្នុងពន្ធនាគារជាមួយម្តាយអាចទទួលផលប៉ះពាល់ផ្នែកផ្លូវកាយ និងផ្លូវអារម្មណ៍ទាំងម្តាយ និងកូន។ ច្បាប់អន្តរជាតិ (វិធានបាងកក) សង្កត់

CC BY NC SA

ធ្ងន់ថា ស្ថានភាពជាក់លាក់របស់ស្ត្រីគួរត្រូវបានពិចារណានៅពេលដែលធ្វើសេចក្តីសម្រេចពីការឃុំខ្លួន ជាពិសេសក្នុងករណីឃុំខ្លួនបណ្តោះអាសន្ន។ ស្ត្រីមានផ្ទៃពោះ និងស្ត្រីជាម្តាយមានកូន ដែលជាទម្លាប់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ដោយមិនបានពិចារណាពីស្ថានភាពរបស់ពួកគេ ឬមិនបានពិចារណាពីសុខុមាលភាពរបស់ម្តាយ និងកូន។ ដូចដែលបង្ហាញ នៅខែកក្កដា ឆ្នាំ២០១៨ ក្នុងចំណោមស្ត្រីដែលជាម្តាយចំនួន១៣៥នាក់ កូនតូចចំនួន១៣៨នាក់ និងស្ត្រីមានផ្ទៃពោះចំនួន៣០នាក់ ជាប់ឃុំនៅក្នុងពន្ធនាគារកម្ពុជា ដែលពាក់កណ្តាលនៃពួកគេត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ចំនួនជនជាប់ឃុំ នៅក្នុងពន្ធនាគារកម្ពុជារួមមានចំនួនស្ត្រីជាប់ពន្ធនាគារកើនឡើងខ្ពស់ចាប់តាំងពីរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមយុទ្ធនាការ“ប្រយុទ្ធប្រឆាំងគ្រឿងញៀន” ក្នុងឆ្នាំ២០១៧ ដែលជាង៧០%នៃស្ត្រីបានប្រព្រឹត្តិបទល្មើសគ្រឿងញៀន។ នៅឆ្នាំ២០១៩ គណៈកម្មាធិការស៊ី-ដ បានបង្ហាញនូវការព្រួយបារម្ភទៅលើកង្វះខាតនៃការពិចារណាដែលផ្តល់ដោយតុលាការកម្ពុជាទៅលើស្ថានភាពជាក់លាក់របស់ស្ត្រីនៅពេលធ្វើការសម្រេចចិត្តអំពីការជាប់ឃុំដែលនាំឱ្យមានការឃុំខ្លួនស្ត្រីដោយមិនចាំបាច់ រួមមានស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូនតូច និងជះឥទ្ធិពលយ៉ាងខ្លាំងទៅកុមារ ដែលត្រូវបានទុកចោលដោយគ្មានអ្នកថែរក្សា ឬក៏ជាប់ឃុំជាមួយម្តាយរបស់ពួកគេក្នុងលក្ខខណ្ឌមិនគ្រប់គ្រាន់។ កង្វះខាតនៃការទទួលបានសេវាថែរក្សាសុខភាពនៅក្នុងពន្ធនាគារប្រទេសកម្ពុជា ជាពិសេសអ្នកជាប់ឃុំជាស្ត្រីមានផ្ទៃពោះ ក៏ជាមូលហេតុដែលត្រូវបានលើកឡើងដោយគណៈកម្មាធិការស៊ី-ដ ផងដែរ។

លទ្ធផលនៃការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដែលបានធ្វើនៅសាលាឧទ្ធរណ៍ភ្នំពេញចន្លោះពី ថ្ងៃទី១ ខែមករា និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បង្ហាញថាជនជាប់ចោទជាស្ត្រីចំនួន ១៨នាក់ (ក្នុងចំណោមជនជាប់ចោទចំនួន ១១៨នាក់) ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១៤ ដែលបានសង្កេតការណ៍ (ក្នុងចំណោមសំណុំរឿងចំនួន ៨៥) ហើយចំនួន ៥៦% នៃជនជាប់ចោទជាស្ត្រី (១០ នាក់ក្នុងចំណោម ១៨ នាក់) ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

ជនជាប់ចោទជាស្ត្រីដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍ក្នុងឆ្នាំ២០២១




## ការសន្មតទុកជាមុនថាគ្មានទោសនៃជនជាប់ចោទជាស្ត្រី

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិមូលដ្ឋានសម្រាប់បុគ្គលគ្រប់គ្នា រួមមានជនជាប់ចោទជាស្ត្រី ដែលស្ថិតនៅក្រោមច្បាប់ជាតិ និងអន្តរជាតិ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជាចែងថា *“ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។”* មាត្រានេះចែងតាមមាត្រា១៤(២) នៃ ក.អ.ស.ព.ន ដែលចែងថា *“ជនដែលជាប់ចោទពីព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានកំណត់ដោយច្បាប់។”* សិទ្ធិនេះបង្ហាញយ៉ាងច្បាស់ពីវិធីផ្សេងៗ និងរួមបញ្ចូលសិទ្ធិបង្ហាញខ្លួនចំពោះមុខតុលាការដោយលក្ខណៈធម្មតា និងសេចក្តីថ្លៃថ្នូរក្នុងសភាពជាជនមានសេរីភាព និងឥតទោស។

ប៉ុន្តែ នៅក្នុងប្រទេសកម្ពុជា ជនជាប់ចោទជាច្រើនបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារ រួមមានឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិត ដែលផ្ទុយនឹងការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ។ ក្នុងចំណោមជនជាប់ចោទជាស្ត្រី ពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍នៅឆ្នាំ២០២១ ជនជាប់ចោទចំនួន ១៤នាក់ មានវត្តមាននៅពេលសវនាការ (ចំនួន ៧៨%) ដែលប្រាំបួននាក់បានស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ (ចំនួន ៥០%)។ ជាសរុបចំនួន ៣៣% (៦ នាក់ ក្នុងចំណោម ១៨ នាក់) នៃជនជាប់ចោទជាស្ត្រីបានស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិត ខណៈដែលចំនួន ១៧% (៣ នាក់ ក្នុងចំណោម ១៨ នាក់) បង្ហាញខ្លួនចំពោះមុខតុលាការដោយស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។

ជនជាប់ចោទជាស្ត្រីដែលបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារនៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍នៅឆ្នាំ២០២១




*មិនពាក់ព័ន្ធ សំដៅដល់ជនជាប់ចោទជាស្ត្រី ដែលអវត្តមាននៅពេលសវនាការឬ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

## សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវីរបស់ជនជាប់ចោទជាស្ត្រី

សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី គឺជាសិទ្ធិមូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបាន

cc BY NC SA

ជានាដល់ជនគ្រប់រូប រួមមានជនជាប់ចោទជាស្ត្រី។ សិទ្ធិមានវត្តមាននៅពេលសវនាការគឺចាំបាច់ ដោយសារតែសិទ្ធិនេះអនុញ្ញាតឱ្យជនជាប់ចោទស្តាប់សំណុំរឿងប្រឆាំងនឹងខ្លួន និងដើម្បីបង្ហាញការការពារខ្លួន។ សវនាការដោយគ្មានជនជាប់ចោទបង្ហាញខ្លួន រារាំងនូវសមត្ថភាពរបស់ពួកគេដើម្បីការពារខ្លួន។ ការជំនុំជម្រះកំបាំងមុខអាចអនុញ្ញាតបានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ តែក្នុងកាលៈទេសៈពិសេស និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវ។ ប្រសិនបើលក្ខខណ្ឌទាំងនោះមិនទទួលបានលប្រយោជន៍យុត្តិធម៌ទេនោះ ការអវត្តមានជនជាប់ចោទធ្វើឱ្យការជំនុំជម្រះមិនស្របច្បាប់។

ដើម្បីបង្ហាញនូវការការពារដែលមានប្រសិទ្ធភាព ជាការសំខាន់ដែលជនជាប់ចោទអាចទទួលបានមេធាវី ដើម្បីតំណាងឱ្យពួកគេ ដោយសារតែនីតិវិធីច្បាប់មានភាពស្មុគស្មាញ និងគ្មានជំនួយផ្នែកច្បាប់ដែលមានគុណសម្បត្តិត្រឹមត្រូវ ជនជាប់ចោទអាចខ្វះខាតចំណេះដឹងផ្នែកច្បាប់ និងប្រព័ន្ធតុលាការក្នុងការការពារខ្លួនដោយសមស្របនៅពេលសវនាការ។ ការនៅមានកម្រិតផ្នែកហិរញ្ញវត្ថុមិនគួររារាំងជនជាប់ចោទពីការទទួលបានមេធាវីនោះទេ។ ដោយសារតែបុគ្គលមិនអាចលៃលកលើការចំណាយសម្រាប់មេធាវី ច្បាប់ចែងថាអាជ្ញាធរពាក់ព័ន្ធគួរតែផ្តល់មេធាវីដោយឥតគិតថ្លៃ។

សិទ្ធិទាំងអស់នេះ មានចែងទាំងក្នុងច្បាប់ជាតិ និងអន្តរជាតិ។ មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "*ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលដែលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីលក្ខន្តិកៈមេធាវី*" មាត្រា១៤(៣)(ឃ) នៃ ក.អ.ព.ស.ន ចែងថា "*ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួននិងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នោះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។*"

ទោះបីជាយ៉ាងនេះក្តី ច្បាប់កម្ពុជាចែងពីជំនួយមេធាវីថាជាកាតព្វកិច្ចនៅក្នុងកាលៈទេសៈពីរយ៉ាងប៉ុណ្ណោះ។ យោងតាមមាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការមានមេធាវីគឺចាំបាច់ ប្រសិនបើសំណុំរឿងពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ/និងប្រសិនបើជនជាប់ចោទជាអនីតិជន។ ច្បាប់កម្ពុជាមិនបានចែងពីកាតព្វកិច្ចនៃការមានមេធាវីចំពោះជនជាប់ចោទជានីតិជនជាប់ចោទពីបទមជ្ឈិម ឬបទលហុនោះឡើយ។ នេះផ្ទុយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលតម្រូវចំពោះសិទ្ធិមានមេធាវី ដែលជាការអនុវត្តជាសកល ដោយមិនបែងចែកប្រភេទនៃបទល្មើសឡើយ។ បន្ថែមពីនេះទៀត បើទោះជារដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងក្នុងរយៈពេលថ្មីៗនេះ ដើម្បីបង្កើនជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាក៏ដោយ ការទទួលបានមេធាវីដោយឥតគិតថ្លៃនៅមានកម្រិតសម្រាប់ជនជាប់ចោទក្រីក្រជាច្រើន ដោយសារកង្វះខាតគោលនយោបាយជំនួយផ្នែកច្បាប់ជាតិ ថវិកាដែលផ្តល់សម្រាប់ជំនួយផ្នែកច្បាប់មិនគ្រប់គ្រាន់ និងកង្វះមេធាវីសម្រាប់ជំនួយផ្នែកច្បាប់។ បញ្ញត្តិជំនួយផ្នែកច្បាប់របស់កម្ពុជាមិនគ្រប់គ្រាន់ក៏បានជះឥទ្ធិពលវិសមាមាត្រទៅលើស្ត្រី ជាពិសេសស្ត្រីនៅតាមជនបទ។

ក្នុងចំណោមជនជាប់ចោទជាស្ត្រីចំនួន ១៨ នាក់ ជាប់ពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍នៅឆ្នាំ២០២១ ចំនួន ២២% (៤ នាក់ ក្នុងចំណោម ១៨ នាក់) មិនមានវត្តមានក្នុងសវនាការ។ បន្ថែមពីនេះ ២៨%(៥ នាក់ក្នុងចំណោម ១៨ នាក់) មិនមានមេធាវីតំណាង។







## សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធ ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯងរបស់ជនជាប់ចោទជាស្ត្រី

ជនជាប់ចោទគ្រប់រូប រួមមានស្ត្រីមានសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធ និងផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង។ ការការពារទាំងពីរបែបនេះមានចែងទាំងនៅក្នុងច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិ និងការពារជនជាប់ចោទជាស្ត្រីពីការបង្ខិតបង្ខំឱ្យសារភាព និងពីទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬការប្រព្រឹត្តបន្ថោកបន្ទាប ឬទណ្ឌកម្មឯទៀត ព្រមទាំងពីការដាក់ពិរុទ្ធលើខ្លួនឯង។ មាត្រា១៤ (៣)(ឆ) នៃ ក.អ.ស.ព.ន ចែងថា "*មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯងឬ សារភាពថាមានពិរុទ្ធ។*" មាត្រា៧ នៃ ក.អ.ស.ព.ន ចែងពីការហាមឃាត់ទារុណកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ឬការប្រព្រឹត្តអំពើបន្ថោកបន្ទាបក្នុងការដាក់ទណ្ឌកម្ម។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាហាមឃាត់ការរំលោភបំពានលើរូបរាងកាយរបស់បុគ្គលណាម្នាក់ និងចែងថាការសារភាពដែលបានមកពីការបង្ខិតបង្ខំលើរូបរាងកាយ ឬផ្លូវចិត្តមិនត្រូវបានចាត់ទុកជាភស្តុតាងនៃពិរុទ្ធនោះឡើយ។ បន្ថែមលើនេះ មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "[...] *ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ[...]។*"

ក្នុងចំណោមជនជាប់ចោទជាស្ត្រីចំនួន ១៨ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ចន្លោះពីថ្ងៃទី១ ខែមករា និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ជនជាប់ចោទជាស្ត្រីចំនួន ០១នាក់ (៥,៥%) បានលើកឡើងថា អំពើហិង្សា ឬទារុណកម្មត្រូវបានប្រើប្រាស់មកលើខ្លួន ដើម្បីទទួលបានការសារភាពចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ នៅអំឡុងពេលដំណាក់កាលស៊ើបអង្កេត ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌។

## **អនុសាសន៍**

ម.ស.ម.ក អំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងចៅក្រមសាលាឧទ្ធរណ៍ភ្នំពេញក្នុងការធានាដូចតទៅ៖

- ចៅក្រមសាលាឧទ្ធរណ៍ភ្នំពេញគួរតែធ្វើការពិចារណាទៅលើស្ថានភាពចាំបាច់របស់ស្ត្រីមុនពេលឃុំខ្លួនបណ្តោះអាសន្នដើម្បីជៀសវាងការឃុំខ្លួនមិនចាំបាច់ចំពោះម្តាយរបស់កុមារ និងស្ត្រីមានផ្ទៃពោះ ព្រមទាំងភាពចង្អៀតណែនពន្ធនាគារ។
- ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃគួរផ្សព្វផ្សាយ និងចេញលិខិតណែនាំច្បាស់លាស់ សម្រាប់ជនជាប់ចោទដែលស្ថិតនៅក្រោមនីតិវិធីព្រហ្មទណ្ឌត្រូវតែអនុញ្ញាតឱ្យបង្ហាញខ្លួនក្នុងសវនាការក្នុងសំលៀកបំពាក់ស៊ីវិលធម្មតា។
- ចៅក្រមនៃសាលាឧទ្ធរណ៍គួរតែធានាថា ជនជាប់ចោទដែលបង្ហាញខ្លួនក្នុងតុលាការដែលស្លៀកពាក់ឯកសណ្ឋានទណ្ឌិត ប្តូរទៅជាឯកសណ្ឋានស៊ីវិលធម្មតាវិញ កំឡុងពេលសួរសវនាការដើម្បីជៀសវាងការសន្មតជាមុនថាមានទោសរបស់ពួកគេ។
- ចៅក្រមនៃសាលាឧទ្ធរណ៍គួរតែពន្យាពេលសវនាការ ប្រសិនបើជនជាប់ចោទមិនមានវត្តមាន បើទោះបីជាពួកគេមានមេធាវីតំណាងក៏ដោយ លុះត្រាតែពួកគេបញ្ជាក់យ៉ាងច្បាស់ និងលះបង់សិទ្ធិពួកគេក្នុងការមានវត្តមាន។
- ចៅក្រមគួរតែគោរពសិទ្ធិមានមេធាវីជារួម ដែលមិនគិតអំពីប្រភេទនៃបទល្មើស ដូចដែលមានចែងតាមច្បាប់អន្តរជាតិ។
- ចៅក្រមនៃសាលាឧទ្ធរណ៍គួរតែស៊ើបអង្កេតភ្លាម និងឱ្យបានដិតដល់ចំពោះការអះអាងណាមួយដោយជនជាប់ចោទថាមានការគំរាមកំហែងទារុណកម្ម ឬអំពើហិង្សាត្រូវបានប្រើប្រាស់លើពួកគេដើម្បីបង្ខិតបង្ខំយកចម្លើយសារភាព។

ព្រឹត្តិបត្រព័ត៌មាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌លេខមុនៗរបស់ ម.ស.ម.ក អាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ លេខ៧ លេខ៨ លេខ៩ លេខ១០ លេខ១១ លេខ១២ លេខ១៣ និង លេខ១៤ )។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៨ ប្រចាំឆ្នាំ២០១៩ ប្រចាំឆ្នាំ២០២០ និង ប្រចាំឆ្នាំ២០២១ របស់ ម.ស.ម.ក ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបង្ហាញពីបេកគំហើញសំខាន់ៗ ដែលបានពីការសង្កេតការណ៍នៅសាសាឧទ្ធរណ៍ភ្នំពេញ ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

CC BY NC SA